ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**កំពង់ផែស្វយ័តក្រុងព្រះសីហនុ**

ថ្ងៃអង្គារ ៨រោច ខែ ភទ្របទ ឆ្នាំ ច សំរឹទ្ធិស័ក ២៥៦២
ខេត្តព្រះសីហនុ, ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៨

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី លទ្ធផលកិច្ចប្រជុំក្រុមប្រឹក្សាភិបាល អាណត្តិទី៧ លើកទី២ របស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ ថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៨

កំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស) សូមជម្រាបជូនវិនិយោគិន និងសាធារណជនមេត្តាជ្រាបថា៖ **នៅថ្ងៃទី០១ ខែ តុលា ឆ្នាំ ២០១៨ វេលាម៉ោង ០៩:០០ ឯកឧត្តម លូ គឹមឈន់** ប្រធានក្រុមប្រឹក្សាភិបាលនៃ កសស បានអញ្ជើញចូលរួមជាអធិបតីដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាភិបាល អាណត្តិទី៧ លើកទី២ នៅសាលប្រជុំទីស្តីការក្រសួងពាណិជ្ជកម្ម ។

នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលនេះ បានប្រកាស ពិនិត្យ និងសម្រេចលើរបៀបវារៈ ដូចខាងក្រោម ៖

១. ក្រុមប្រឹក្សាភិបាលបានឯកភាពលើរបាយការណ៍លទ្ធផលអង្គប្រជុំមុន ។

២. ក្រុមប្រឹក្សាភិបាលបានពិនិត្យ និងឯកភាពលើរបាយការណ៍បូកសរុបលទ្ធផលការងារអាជីវកម្ម ៨ខែ ឆ្នាំ២០១៨ ។

៣.ក្រុមប្រឹក្សាភិបាលបានអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ត្រីមាសទី២ ឆ្នាំ២០១៨ ដែលបានត្រួតពិនិត្យដោយក្រុមហ៊ុនសវនកម្មឯករាជ្យ PWC ។

៤. ក្រុមប្រឹក្សាភិបាលបានអនុម័តលើ គម្រោងផែនការអាជីវកម្ម សេវាកម្ម ហិរញ្ញវត្ថុ ឆ្នាំ២០១៩ ។

៥. ក្រុមប្រឹក្សាភិបាលបានឯកភាពលើសេចក្តីព្រាងក្នុងការបង្កើតគណៈកម្មការសវនកម្ម និងគណៈកម្មការហានិភ័យ ។

៦. សេចក្តីផ្សេងៗ ៖

- ក្រុមប្រឹក្សាភិបាលបានពិនិត្យ និងឯកភាពលើរបាយការណ៍ប្រសិទ្ធិភាពការចំណាយ (Cost Efficiency) ដែលសិក្សាដោយ **កសស** ។
- ក្រុមប្រឹក្សាភិបាលបានលើកឡើងឲ្យ **កសស** សិក្សាពីហានិភ័យផ្សេងៗ (Risk Analysis) ។
- ក្រុមប្រឹក្សាភិបាលឲ្យ **កសស** សហការណ៍សិក្សាអំពីការប្រើប្រាស់តំបន់សេដ្ឋកិច្ចពិសេស (SEZ) ជា Off Dock Yard និងការសិក្សាពីវិធានការ ដោះស្រាយការកកស្ទះនៅច្រកទ្វារ **កសស** ។

- ក្រុមប្រឹក្សាភិបាលឯកភាពលើគោលការណ៍ក្នុងការបន្តសុពលភាពជូលឲ្យលោក តូវ ជីហ្វង ម្ចាស់សណ្ឋាគារ និងភោជនីយដ្ឋានឆ្នេថ្មី ដោយ កសស ត្រូវស្នើសុំការសម្រេចពី **ឯកឧត្តមបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។**

អង្គប្រជុំក្រុមប្រឹក្សាភិបាលបានបញ្ចប់នៅវេលាម៉ោង ១៣:៣០ នាទី នាថ្ងៃ ខែ និងឆ្នាំដដែល ប្រកបដោយបរិយាកាសស្និទ្ធស្នាល និងយកចិត្តទុកដាក់ខ្ពស់ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមវិនិយោគិន និងសាធារណជនទទួលជ្រាបជាព័ត៌មាន ។

**កំពង់ផែស្វយ័តក្រុងព្រះសីហនុ**

តិរៈវិថី សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** សង្កាត់៣ ក្រុងព្រះសីហនុ ខេត្ត ព្រះសីហនុ
Terak Vithei Samdech Akka Moha Sena Padei Techo **Hun Sen,** Sangkat 3
Preah Sihanouk City, Preah Sihanouk Province.
**ទូរស័ព្ទ** : (855)34 933 715 **ទូរសារ** : (855)34 933 693
Phone : (855)34 933 715 Fax : (855)34 933 693
Email: accounting@pas.gov.kh www.pas.gov.kh